01378504

E443/7

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 18 / 01 / 2017
ម៉ោង (Time/Heure): 14:45
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

សាធារណៈ / Public

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៧

**ជូនចំពោះ÷** ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី÷** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន÷** លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង
អង្គភាពគាំពារសាក្សី និង អ្នកជំនាញ
ការិយាល័យរដ្ឋបាល

**កម្មវត្ថុ÷** ការជូនដំណឹងអំពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការមិនស្តាប់សក្ខីកម្មសាក្សីដែលមានលេខសម្ងាត់ 2-TCW-946 (Walter HEYNOWSKI)

១. នៅខែ ឧសភា និងខែ កក្កដា ឆ្នាំ ២០១៤ មេធាវីការពារក្តី នួន ជា បានស្នើសុំពន្លឿនការស្តាប់សក្ខីកម្មសាស្ត្រាចារ្យ Walter Heynowksi តាមរយៈប្រព័ន្ធសោតទស្សន៍ ក្នុងករណីចាំបាច់ ដោយសារគាត់មានវ័យចាស់ជរា (ឯកសារ E305/4.2 ប្រតិចារឹកសវនាការថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៤ ទំព័រ ៣៣)។ នៅថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១៦ មេធាវីការពារក្តី នួន ជា បានដាក់សំណើរបស់ខ្លួនសាជាថ្មីសុំស្តាប់សក្ខីកម្មសាស្ត្រាចារ្យ Heynowksi ជាពិសេស ពាក់ព័ន្ធនឹងឯកសារជាសំណៅដើមដែលបានរកឃើញនៅមន្ទីរសន្តិសុខ ស-២១ រយៈពេលពីរបីខែក្រោយពេលរបបខ្មែរក្រហមដួលរលំ (ឯកសារ E412 កថាខណ្ឌ ២)។ នៅថ្ងៃទី ២១ ខែ កញ្ញា

ឆ្នាំ ២០១៦ អង្គជំនុំជម្រះបានចេញសេចក្ដីសម្រេចមួយទៅលើសំណើជាច្រើនរបស់មេធាវីការពារក្ដី នួន ជា ដែលសុំស្ដាប់សក្ខីកម្មសាក្សីបន្ថែមនៅក្នុងសំណុំរឿង ០០២/០២ ដែលក្នុងនោះមេធាវីការពារក្ដីបានស្នើសុំថា ជំនួសឱ្យការស្ដាប់សក្ខីកម្មសាស្ត្រាចារ្យ Heynowksi មេធាវីការពារក្ដីស្នើសុំព័ត៌មានពីគាត់ពាក់ព័ន្ធនឹងឯកសារមួយចំនួនវិញ (ឯកសារ E443)។

២. ក្រោយមក អង្គជំនុំជម្រះសាលាដំបូងបានទទួលសៀវភៅពណ៌ទឹកក្រូចនៃកំណត់ត្រាប្រចាំថ្ងៃអ្នកជាប់ឃុំ និង រូបថតនៅមន្ទីរសន្តិសុខ ស-២១ ពីសាស្ត្រាចារ្យ Heynowksi ដោយបានផ្ដល់សម្ភារៈទាំងនេះទៅភាគី និងកំណត់ពេលស្ដាប់សេចក្ដីសន្និដ្ឋានផ្ទាល់មាត់ ទៅលើករណីថាតើគួរទទួលយកឯកសារទាំងនេះធ្វើជាភស្តុតាងដែរ ឬទេ (ឯកសារ E443/2, E443/2/1)។ មេធាវីការពារក្ដី នួន ជា បានលើកឡើងថា តើសាស្ត្រាចារ្យ Heynowksi បានបង្ហាញពីបំណងក្នុងការមកផ្ដល់សក្ខីកម្មដែរ ឬទេ (ប្រតិចារឹកសវនាការថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៦ ទំព័រ ៦-៧ (សេចក្ដីព្រាង))។ មេធាវីការពារក្ដី ខៀវ សំផន បានស្នើសុំឱ្យកោះហៅសាស្ត្រាចារ្យ Heynowksi មកផ្ដល់សក្ខីកម្ម ដើម្បីពន្យល់ពីរបៀបទទួលបានឯកសារ និងរក្សាទុកឯកសារទាំងនោះចាប់តាំងពីឆ្នាំ ១៩៨០ មក (ប្រតិចារឹកសវនាការថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៦ ទំព័រ ១១-១៣ (សេចក្ដីព្រាង))។ ចាប់តាំងពីពេលនោះមក ភាគីពុំបានជំទាស់ទៅនឹងការទទួលយកឯកសារទាំងនេះទេ ហើយអង្គជំនុំជម្រះក៏បានទទួលយកសៀវភៅពណ៌ទឹកក្រូចនៃកំណត់ត្រាប្រចាំថ្ងៃអ្នកជាប់ឃុំ ព្រមទាំងរូបថតនៅមន្ទីរសន្តិសុខ ស-២១ ដែលទទួលបានពីសាស្ត្រាចារ្យ Heynowksi ធ្វើជាភស្តុតាង (ឯកសារ E443/3, E443/6)។

៣. នៅថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៧ អង្គជំនុំជម្រះបានជូនដំណឹងដល់ភាគីថា អង្គជំនុំជម្រះពុំមានបំណងនឹងស្ដាប់សក្ខីកម្មសាក្សីបន្ថែមទៀតទេ ហើយថា ថ្ងៃនោះជាថ្ងៃចុងក្រោយនៃសវនាការពិភាក្សាដេញដោលពិនិត្យភស្តុតាងក្នុងសំណុំរឿង ០០២/០២។ ទោះជាយ៉ាងនេះក្ដី អង្គជំនុំជម្រះបានកត់សម្គាល់ថា អង្គជំនុំជម្រះអាចនឹងបើកកិច្ចដំណើរការនីតិវិធីសវនាការឡើងវិញ ដើម្បីស្ដាប់សក្ខីកម្មសាស្ត្រាចារ្យ Heynowksi តាមរយៈប្រព័ន្ធសោតទស្សន៍ ប្រសិនបើដំណើរការរៀបចំនេះអាចធ្វើបានយ៉ាងយូរបំផុតត្រឹមថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៧។

៤. បន្ទាប់ពីបានទទួលការបញ្ជាក់ថា សាស្ត្រាចារ្យ Heynowski មានបំណងចង់ផ្ដល់សក្ខីកម្ម អង្គជំនុំជម្រះសាលាដំបូង បានធ្វើការទាក់ទងជាមួយអាជ្ញាធរនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់

E443/7

ពាក់ព័ន្ធនឹងលទ្ធភាពនៃការស្តាប់សក្ខីកម្មសាស្ត្រាចារ្យ Heynowski តាមរយៈប្រព័ន្ធសោត-ទស្សន៍ពីប្រទេសអាល្លឺម៉ង់។ ទោះបីជាទទួលបានកិច្ចសហការយ៉ាងល្អពីអាជ្ញាធរនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ក៏ដោយ តែអាជ្ញាធរដដែលនេះបានគូសបញ្ជាក់ថា ការស្តាប់សក្ខីកម្មសាក្សីរូបនេះនៅក្នុងបរិវេណអាគារទីភ្នាក់ងារអង្គការសហប្រជាជាតិនៅក្នុងទីក្រុងប៊ែរឡាំងពុំអាចធ្វើទៅបានទេ។ ដោយពិចារណាទៅលើការលំបាកផ្នែកបច្ចេកទេសមួយចំនួនទៀត រួមនឹងលក្ខខណ្ឌផ្នែកនីតិវិធីនៃកិច្ចសហប្រតិបត្តិការតាមផ្លូវតុលាការ ដែលត្រូវចំណាយពេលច្រើន ទើបធ្វើឱ្យអង្គជំនុំជម្រះសន្និដ្ឋានថា ការស្តាប់សក្ខីកម្មសាក្សីរូបនេះពុំអាចធ្វើបានទៅតាមពេលវេលាកំណត់ត្រឹមថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៧ ដែលអង្គជំនុំជម្រះបានប្រកាសឡើយ។ ហេតុនេះ អង្គជំនុំជម្រះជូនដំណឹងដល់ភាគីថា កិច្ចដំណើរការនីតិវិធីសវនាការនឹងពុំបើកដំណើរការឡើងវិញ ដើម្បីស្តាប់សក្ខីកម្មសាក្សីរូបនេះទេ។

៥. អង្គជំនុំជម្រះនឹងផ្តល់សំអាងហេតុពេញលេញនៃសេចក្តីសម្រេចបដិសេធសំណើសុំស្តាប់សក្ខី-កម្មសាស្ត្រាចារ្យ Heynowksi នៅក្នុងពេលវេលាសមស្របខាងមុខ។